ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការបរទេស
និងសហប្រតិបត្តិការអន្តរជាតិ

# សេចក្តីប្រកាសព័ត៌មាន
## ស្តីពីលទ្ធផលនៃកិច្ចប្រជុំកំពូលនៃកិច្ចសហប្រតិបត្តិការមេគង្គ-ឡានឆាងលើកទី ២

(រាជធានីភ្នំពេញ, ថ្ងៃទី ១០ ខែមករា ឆ្នាំ ២០១៨)

------------------

តាមការអញ្ជើញរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា **ឯកឧត្តម លី ខឺឈាង** នាយករដ្ឋមន្ត្រីនៃសាធារណរដ្ឋប្រជាមានិតចិន **ឯកឧត្តម ថងលូន ស៊ីស៊ូលីត** នាយករដ្ឋមន្ត្រីនៃសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ **ឯកឧត្តម មិន ស្វេ** អនុប្រធានាធិបតីនៃសាធារណរដ្ឋសហភាពមីយ៉ាន់ម៉ា **ឯកឧត្តមនាយឧត្តមសេនីយ៍ ប្រាយុទ្ធ ច័ន្ទអូចា** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រថៃ និង**ឯកឧត្តម ង្វៀន សួនហ៊ុក** នាយករដ្ឋមន្ត្រីនៃសាធារណរដ្ឋសង្គមនិយមវៀតណាម បានដឹកនាំគណៈប្រតិភូមកចូលរួមកិច្ចប្រជុំកំពូលនៃកិច្ចសហប្រតិបត្តិការមេគង្គ-ឡានឆាងលើកទី២ នៅថ្ងៃទី ១០ ខែមករា ឆ្នាំ២០១៨ នៅវិមានសន្តិភាព រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា។

**សម្តេចតេជោនាយករដ្ឋមន្ត្រី ហ៊ុន សែន** និង**ឯកឧត្តម លី ខឺឈាង** បានធ្វើជាសហប្រធានដឹកនាំដោយជោគជ័យនូវកិច្ចប្រជុំជាប្រវត្តិសាស្ត្រនេះ ក្រោមមូលបទ **"ទន្លេរបស់យើងដើម្បីសន្តិភាព និងការអភិវឌ្ឍប្រកបដោយចីរភាព"** នៅក្នុងដំណាក់កាលដ៏មានសារៈសំខាន់ដែលយន្តការថ្មីនេះកំពុងវិវត្តពី "ដំណាក់កាលកសាងមូលដ្ឋានគ្រឹះ" ទៅ "ដំណាក់កាលរីកលូតលាស់" ដោយមានរបៀបវារៈនៃភាពជាដៃគូ និងកិច្ចសហប្រតិបត្តិការប្រកបដោយមហិច្ឆតាខ្ពស់។

ក្នុងនាមជាម្ចាស់ផ្ទះ និងជាសហប្រធាននៃកិច្ចប្រជុំ **សម្តេចតេជោនាយករដ្ឋមន្ត្រី ហ៊ុន សែន** បានលើកឡើងអំពីសារៈសំខាន់នៃសន្តិភាពប្រកបដោយនិរន្តរភាព និងការអភិវឌ្ឍប្រកបដោយចីរភាពយូរអង្វែងនៅតំបន់មេគង្គ ដែលកាលពីអតីតកាលធ្លាប់ត្រូវបានបំផ្លិចបំផ្លាញខ្ទេចខ្ទាំដោយសារសង្គ្រាម និងការប្រកួតប្រជែងនៃមនោគមវិជ្ជា។ **សម្តេចតេជោនាយករដ្ឋមន្ត្រី** បានលើកឡើងពីសមិទ្ធផលដ៏វិសេសវិសាលនៃតំបន់មេគង្គក្នុងការសម្រេចបាននូវសន្តិសហវិជ្ជមាន តាមរយៈការគោរពទៅវិញទៅមក ចំពោះបូរណភាពទឹកដី និង អធិបតេយ្យភាពរបស់ប្រទេសនីមួយៗ និងការមិនជ្រៀតជ្រែកកិច្ចការផ្ទៃក្នុងរបស់គ្នាទៅវិញទៅមក។ ស្មារតីនេះពិតជាមានសង្គតិភាពជាមួយគុណតម្លៃនៃកិច្ចសហប្រតិបត្តិការមេគង្គ-ឡានឆាង ដែលប្រកាន់ខ្ជាប់នូវគោលការណ៍ឯកភាពមតិជាឯកច្ឆន្ទ សមភាព ការពិគ្រោះយោបល់ និងការសម្របសម្រួលគ្នាទៅវិញទៅមក ការស្ម័គ្រចិត្ត ការចូលរួមជាមួយគ្នា និងផលប្រយោជន៍រួម ព្រមទាំងការគោរពចំពោះធម្មនុញ្ញអង្គការសហប្រជាជាតិ និងច្បាប់អន្តរជាតិនានា។

អាសយដ្ឋាន: លេខ ៣ វិថី សម្តេច ហ៊ុន សែន
សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ : (855) 23 214 441, 216 122
ទូរសារ : (855) 23 216 144, 216 141
អ៊ីម៉ែល : mfaic@mfa.gov.kh

នៅក្នុងកិច្ចប្រជុំនេះ ប្រមុខដឹកនាំទាំងអស់ បានពិនិត្យឡើងវិញនូវវឌ្ឍនភាពដែលសម្រេចបានស្រប តាមទិសដៅនៃសេចក្តីថ្លែងការណ៍ក្រុងសានយ៉ា ដែលបានអនុម័តនៅក្នុងកិច្ចប្រជុំកំពូលលើកទី១ នៅទីក្រុងសានយ៉ា ប្រទេសចិន កាលពីខែមីនា ឆ្នាំ២០១៦។

ប្រមុខដឹកនាំទាំងអស់ បានអបអរសាទរចំពោះការបង្កើតលេខាធិការដ្ឋានជាតិ/អង្គភាពសម្របសម្រួលនៃកិច្ចសហប្រតិបត្តិការមេគង្គ-ឡានឆាង នៅក្នុងប្រទេសទាំង៦មុនកាលបរិច្ឆេទដែលបានកំណត់ ការទទួលនិងការអនុម័តលើបញ្ជីគម្រោងដំណាក់កាលទី១ នៃមូលនិធិពិសេសនៃកិច្ចសហប្រតិបត្តិការមេគង្គឡានឆាង ការបង្កើតនិងដំណើរការនៃក្រុមការងាររួមតាមវិស័យអាទិភាពគន្លឹះទាំង៦ ការបង្កើតមជ្ឈមណ្ឌលកិច្ចសហប្រតិបត្តិការធនធានទឹក មជ្ឈមណ្ឌលកិច្ចសហប្រតិបត្តិការបរិស្ថានមេគង្គ-ឡានឆាង និង មជ្ឈមណ្ឌលសកលសម្រាប់ការសិក្សាទន្លេមេគង្គ។

ប្រមុខដឹកនាំទាំងអស់ បានកត់សម្គាល់ដោយសេចក្តីសោមនស្ស ដោយគម្រោងឆាប់ទទួលបានផលភ្លាមៗទាំង៤៥ និងគំនិតផ្តួចផ្តើមទាំង១៣ ដែលបានដាក់ចេញដោយប្រទេសចិននៅក្នុងកិច្ចប្រជុំកំពូលមេគង្គ-ឡានឆាងលើកទី១ និងរដ្ឋមន្ត្រីការបរទេសមេគង្គ-ឡានឆាងលើកទី២ ត្រូវបានបញ្ចប់ ឬសម្រេចបានវឌ្ឍនភាពគួរឲ្យកត់សម្គាល់។ ជាមួយនឹងការចាប់ផ្តើមដំណើរការនៃមូលនិធិពិសេសមេគង្គ-ឡានឆាង ដោយប្រទេសចិន សម្រាប់ការគាំទ្រគម្រោងខ្នាតតូច និងមធ្យម ប្រមុខដឹកនាំទាំងអស់បានបង្ហាញនូវការពេញចិត្ត ដោយគម្រោងចំនួន១៣២ នៅក្នុងបញ្ជីគម្រោងដំណាក់កាលទី១ដែលគាំទ្រដោយមូលនិធិពិសេសមេគង្គ-ឡានឆាងឆ្នាំ២០១៧ ត្រូវបានអនុវត្តជាបន្តបន្ទាប់។

បន្ថែមលើការរីកចម្រើនទាំងនេះ ប្រមុខដឹកនាំទាំងអស់បានឈានដល់ការឯកភាពមតិជាឯកច្ឆន្ទ និងបានអនុម័តឯកសារសមិទ្ធផលសំខាន់ចំនួន២ គឺសេចក្តីថ្លែងការណ៍ក្រុងភ្នំពេញនៃកិច្ចប្រជុំកំពូលកិច្ចសហប្រតិបត្តិការមេគង្គ-ឡានឆាងលើកទី២ និងផែនការសកម្មភាព៥ឆ្នាំនៃកិច្ចសហប្រតិបត្តិការមេគង្គ-ឡានឆាង (២០១៨-២០២០)។ ប្រមុខដឹកនាំទាំងអស់បានកត់សម្គាល់បញ្ជីគម្រោងដំណាក់កាលទី២ ដែលនឹងត្រូវគាំទ្រដោយមូលនិធិពិសេសមេគង្គ-ឡានឆាងឆ្នាំ២០១៨ និងរបាយការណ៍វឌ្ឍនភាពនៃក្រុមការងាររួមតាមវិស័យអាទិភាពគន្លឹះទាំង៦។

កិច្ចប្រជុំក៏បានកត់សម្គាល់ពីការចប់អាណត្តិភាពជាសហប្រធានដែលមានរយៈពេលពីរឆ្នាំរបស់កម្ពុជា ដោយមានចិនជាសហប្រធានអចិន្ត្រៃយ៍។ នៅចុងបញ្ចប់នៃកិច្ចប្រជុំ **សម្តេចតេជោនាយករដ្ឋមន្ត្រី** បានប្រគល់ប្រវាទូកដែលជានិមិត្តសញ្ញានៃភាពជាសហប្រធាននៃកិច្ចសហប្រតិបត្តិការមេគង្គ-ឡានឆាង ជូន **ឯកឧត្តម ថងលូន ស៊ីស៊ូលីត** នាយករដ្ឋមន្ត្រីនៃសាធារណរដ្ឋប្រជាមានិតប្រជាធិបតេយ្យឡាវ ក្នុងឋានៈជាសហប្រធានបន្ទាប់។

ក្នុងអំឡុងពេលនៃកិច្ចប្រជុំកំពូលនេះ **សម្តេចតេជោនាយករដ្ឋមន្ត្រី** បានជួបប្រជុំទ្វេភាគីជាមួយ **ឯកឧត្តម ង្វៀន សួនហ៊ុក ឯកឧត្តមនាយឧត្តមសេនីយ៍ ប្រាយុទ្ធ ច័ន្ទអូចា** និង**ឯកឧត្តម ថងលូន ស៊ីស៊ូលីត**។

ថ្ងៃព្រហស្បតិ៍ ១០ រោច ខែបុស្ស ឆ្នាំរកា នព្វស័ក ព.ស. ២៥៦១
រាជធានីភ្នំពេញ ថ្ងៃទី ១១ ខែមករា ឆ្នាំ២០១៨